ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៣៣ គ.ជ.ប.ន.ស.ន

សេចក្តីណែនាំ
ស្តីពី
កិច្ចសហការ និងវិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងសេចក្តីសម្រេចលេខ០២៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងសេចក្តីសម្រេចលេខ៣៩៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពនៃលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងសេចក្តីសម្រេចលេខ០០៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦
- យោងផែនការអនុវត្តលេខ០៦៨ គសអ ផ.ក/២៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៦ រវាងគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីគោលការណ៍ និងសកម្មភាពរួមក្នុងការត្រៀមរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមនីតិកាល និងអាណត្តិនីមួយៗ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០
- យោងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

ដើម្បីឱ្យដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៦ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ស្ថិតក្នុងបរិយាកាសនយោបាយស្ងប់ស្ងាត់ ប្រកបដោយសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមណែនាំដល់ លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) និងក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ត្រូវសហការអនុវត្តតាមគោលការណ៍ និងវិធានការដូចតទៅ៖

១. លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខរចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំកម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬ/និងផ្នែកអាវុធហត្ថរាជធានី

មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia
ទូរសព្ទ : (+855) 23 23 52 53
អ៊ីម៉ែល : info@nec.gov.kh

ខេត្ត ឱ្យបំពេញការកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត និងចាត់វិធានការចាំបាច់នានា ដើម្បីការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៦ ដោយអនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ផែនការអន្តរស្ថាប័នលេខ០៦៨ គសអ ផ.ក/២៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៦ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីណែនាំអំពីការងារសន្តិសុខបោះឆ្នោតផ្សេងៗទៀតរបស់ គ.ស.អ និង គ.ជ.ប។

២. **លធ.ខប កបយ.ស** និង **ក.ច.ប** នីមួយៗ ត្រូវពង្រឹងកិច្ចសហការការងារឱ្យបានជាប្រចាំជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាសេនាធិការ ពិសេសកម្លាំងប្រចាំការត្រៀមនៅតាមរាជធានី ខេត្ត កម្លាំងត្រៀមអន្តរាគមន៍ក្នុងភូមិសាស្ត្រខាងក្រៅនៃក្រុង ស្រុក ខណ្ឌនីមួយៗ និងកម្លាំងការពារនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ដែលមានទីតាំងនៅតាមសាលាឃុំ សង្កាត់ ឬចល័តទៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ផ្អែកតាមផែនការដែលបានកំណត់។

៣. **លធ.ខប កបយ.ស** និង **ក.ច.ប** នីមួយៗ ត្រូវយកចិត្តទុកដាក់តាមដាន និងក្តាប់ជាប់សភាពការណ៍សន្តិសុខ និងត្រូវស្នើសុំកិច្ចអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ចដែលពាក់ព័ន្ធ ក្រុមពន្លត់អគ្គិភ័យ ឬក្រុមបុគ្គលិកសុខាភិបាលឱ្យបានទាន់ពេលវេលា ក្នុងករណីមានការអុកឡុកវឹខាន ការគំរាមកំហែង ឬការប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេងៗទៀត ក្នុងករណីកើតមានអសន្តិសុខ ឬអគ្គិភ័យ ឬបញ្ហាសុខភាពផ្សេងៗ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

៤. ក្នុងករណីប្រទេសជាតិជួបគ្រោះអាសន្ន ឬស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ **គ.ជ.ប លធ.ខប កបយ.ស** និង **ក.ច.ប** នីមួយៗ ត្រូវយកចិត្តទុកដាក់អនុវត្តតាមវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងទៀត ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗ។

៥. ចាប់ពីពេលនេះ រហូតដល់បញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ **លធ.ខប** នីមួយៗ ត្រូវរៀបចំកិច្ចប្រជុំចម្រុះដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ (Online) ក្នុងមួយខែម្តង ឬពីរដងតាមការចាំបាច់ និងអាចប្រជុំជាវិសាមញ្ញ ក្នុងគោលបំណងពិភាក្សាលើការងារសន្តិសុខ និងការចាត់វិធានការចាំបាច់ផ្សេងៗ សំដៅកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬការប្រឈមនានា ដែលបានកើតឡើង និងស្វែងរកដំណោះស្រាយឱ្យបានសមស្រប និងទាន់ពេលវេលា។

សមាសភាពដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាខាងលើ រួមមាន៖

- ប្រធាន លធ.ខប ជាសហប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធាន គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ឬតំណាង ជាសហប្រធាន
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស យោធភូមិភាគទី១ ដល់ទី៥ នៃរាជធានី ខេត្តដែលពាក់ព័ន្ធ ឬតំណាង ជាសមាជិក
- មេបញ្ជាការតំបន់សឹករងរាជធានី ខេត្ត ជាសមាជិក
- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត ជាសមាជិក
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងជាប្រធាន គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬតំណាង ជាសមាជិក

- តំណាងគណបក្សនយោបាយប្រចាំរាជធានី ខេត្ត ជាសមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធប្រចាំរាជធានី ខេត្ត ជាសមាជិក
- អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ (ប្រសិនបើមាន) ជាសមាជិក ឬ/និង
- មន្ត្រីតំណាងរបស់លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប តាមការចាត់តាំងភាគីពាក់ព័ន្ធផ្សេងទៀតមួយចំនួនតាមការចាំបាច់។

៦. **លធ.ខប** នីមួយៗ ត្រូវធ្វើរបាយការណ៍ជាប្រចាំជុំវិញស្ថានការណ៍សន្តិសុខ ដែលបានកើតឡើងនៅរាជធានី ខេត្តនីមួយៗ ក្នុងអំឡុងពេលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ផ្ញើជូនលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ឱ្យបានទៀងទាត់ ហើយក្នុងករណីចាំបាច់ **លធ.ខប** ត្រូវរាយការណ៍ដោយផ្ទាល់ជូនប្រធានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ដើម្បីស្នើសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំ **គ.ជ.ប** និងមានវិធានការដោះស្រាយបានទាន់ពេលវេលា និងស្របតាមនីតិវិធី។

ទទួលបានសេចក្តីណែនាំនេះ **ប្រធានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ប្រធាន លធ.ខប ប្រធាន កបយ.ស** និង**ប្រធាន ក.ច.ប** ទាំងអស់ត្រូវយកចិត្តទុកដាក់សហការអនុវត្តឱ្យមានប្រសិទ្ធភាព និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១រោច ខែ ស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២៦
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ប្រាជ្ញ ចន្ទ

<u>កន្លែងទទួល</u>ៈ
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ)
- លេខាធិការដ្ឋាន នៃ គ.ស.អ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គណៈអភិបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងជា គណៈបញ្ជាការឯកភាពរដ្ឋបាល
- បញ្ជាការដ្ឋានយោធភូមិភាគពិសេស និងយោធភូមិភាគទាំងប្រាំ
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត
- បញ្ជាការដ្ឋានតំបន់សឹករងរាជធានី ខេត្ត

"<u>ដើម្បីជូនជ្រាប ផ្សព្វផ្សាយ និងសហការអនុវត្ត</u>"
- ឯកសារ កាលប្បវត្តិ